# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញជាអធិបតី ក្នុងសិក្ខាសាលា ស្តីពី សុពលភាពប្រកាសនីយបត្រតក្កកម្មរបស់ការិយាល័យ ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប




នៅព្រឹកថ្ងៃទី ១១ ខែ មករា ឆ្នាំ២០១៦ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានអញ្ជើញជាអធិបតីក្នុងសិក្ខាសាលា ស្តីពីសុពលភាពប្រកាសនីយបត្រតក្កកម្មរបស់ ការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប នៅសាលប្រជុំរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ។

បន្ទាប់ពីមតិស្វាគមន៍ និងចំណាប់អារម្មណ៍របស់លោក **ង៉ែត វិបុល** អគ្គនាយករង នៃអគ្គនាយកដ្ឋានឧស្សាហកម្ម ទទួលបន្ទុកការងារកម្មសិទ្ធិឧស្សាហកម្ម និងចំនាប់អារម្មណ៍របស់លោក **Pascal Phlix** អ្នកសម្របសម្រួលសម្រាប់ ប្រទេសអាស៊ាន អឺរ៉ុបភាគខាងត្បូង និងប្រទេសអាហ្វ្រិកកណ្តាល និងភាគខាងលិចរួចមក មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងនូវទឹកចិត្តរីករាយ ចំពោះការចូលរួមជាអាធិបតី ក្នុងពិធីបើកសិក្ខាសាលា ស្តីពី សុពលភាពប្រកាសនីយបត្រតក្កកម្មរបស់ការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប នាថ្ងៃនេះ ។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាម ឯកឧត្តមផ្ទាល់ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានសម្តែងនូវការកោតសរសើរដ៏ស្មោះស ចំពោះ មន្ត្រីជំនាញ នៃអគ្គនាយកដ្ឋានឧស្សាហកម្ម របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ក្នុងការខិតខំប្រឹងប្រែងសហការគ្នា ដើម្បីរៀបចំសិក្ខាសាលា ដ៏មានសារៈសំខាន់ តាមសំណើររបស់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។




ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា: នេះជាលើកទី១ហើយ ដែលក្រសួងឧស្សាហកម្ម និងសិប្បកម្មកម្ពុជា បានរៀបចំសិក្ខាសាលា ស្តីពីសុពលភាពប្រកាសនីបត្រតក្កកម្មរបស់ការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ក្រោមការគាំទ្រ និងសហការពីការរយាល័យប្រកាសនីយត្រតកក្កកម្មអឺរ៉ុប ដែលមានលោក **Pascal Phix** អ្នកសម្របសម្រួលសម្រាប់ប្រទេសអាស៊ាន អឺរ៉ុបភាគខាងត្បូង និងប្រទេសអាហ្វ្រិកកណ្តាល និងភាគខាងលិច។




ក្នុងបរិបទសាកលភាវូបនីយកម្មសេដ្ឋកិច្ច និងការចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន នាបច្ចុប្បន្ននេះ កម្មសិទ្ធិបញ្ញាគឺជាកម្មវត្ថុមួយដ៏មានសារៈសំខាន់ សម្រាប់ការធ្វើពាណិជ្ជកម្ម ការជម្រុញផលិតកម្ម ឧស្សាហកម្ម ជម្រុញការប្រកួតប្រជែងក្នុងទីផ្សារក្នុងប្រទេស តំបន់ និងអន្តរជាតិ និងធ្វើឱ្យកាន់តែរីកចម្រើន ។ ក្នុងនោះប្រកាសនីយបត្រតក្កកម្ម ដែលការពារកម្មសិទ្ធិបញ្ញាចំពោះរបបគំហើញការច្នៃប្រឌិត បច្ចេកវិទ្យាថ្មីៗ ក៏ដើរតួចម្បង ក្នុងការចូលរួមចំណែកពង្រឹង និងពង្រីក ក្នុងកិច្ចការពារកម្មសិទ្ធបញ្ញានេះដែរ ។



ការស្វែងយល់អំពីការផ្តល់ និងកិច្ចការពារប្រកាសនីយបត្រតក្កកម្មរបស់ការិយាល័យអឺរ៉ុបនាពេលនេះ នឹងផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់ការងារប្រកាសនីយបត្រតកក្កកម្មរបស់យើងដកស្រង់បទពិសោធន៍ ដែលគេបានឆ្លងកាត់ជាយូរមកហើយរហូតដល់ការរីកធំធាត់ក្លាយជាការិយាល័យធំមួយ ក្នុងពិភពលោក ផ្នែកប្រកាសនីយត្រតក្កកម្ម ។

ការិយាល័យប្រកាសនីយបត្រអឺរ៉ុបមានអ្នកត្រួតពិនិត្យប្រកាសនីយបត្រតក្កកម្ម ដែលមានជំនាញផ្សេងៗគ្នាជាច្រើន ហើយអាចផ្តល់ប្រកាសនីយបត្របានច្រើនក្នុងមួយឆ្នាំៗ ។

ការធ្វើកិច្ចសហប្រតិបត្តិការលើការងារប្រកាសនីយបត្រតក្កកម្ម ជាមួយការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដោយការផ្តល់សុពលភាពចំពោះប្រកាសនីយបត្រតក្កកម្ម ដេលចេញដោយការិយាល័យអឺរ៉ុប សម្រាប់ការពារនៅកម្ពុជា គឺជាកត្តាមួយ ដែលមានប្រយោជន៍ចំពោះកម្ពុជា ដែលយើងមានការខ្វះខាតអ្នកជំនាញ ក្នុងការពិនិត្យប្រកាសនីយបត្រតក្កកម្ម ។ ការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុបជាអ្នកទទួលពាក្យសុំ ពិនិត្យ ចេញប្រកាសនីយបត្រតក្កកម្ម រួចផ្ញើមកកម្ពុជា ហើយឈរលើមូលដ្ឋាននេះ កម្ពុជានឹងចេញវិញ្ញាបនបត្រតក្កកម្ម ដោយមិនចាំបាច់ធ្វើការពិនិត្យលម្អិតថែមទៀត ទេ ។ ព្រឹត្តិការណ៍នេះ នឹងផ្តល់លទ្ធភាពឱ្យយើងទទួលបានពាក្យសុំការពារប្រកាសនីយបត្រតក្កកម្មច្រើន បង្កើនប្រាក់ចំណូល និងអាចទទួលបានការវិនិយោគលើបច្ចេកវិទ្យាថ្មីៗច្រើន ។

រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ** ហ៊ុន សែន នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញឱ្យអនុវត្តនូវយុទ្ធសាស្រ្តចតុកោណដំណាក់

កាលទី៣ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ក្រសួងនឹងបន្តខិតខំធ្វើយ៉ាងណាឱ្យកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ជាពិសេសផ្នែកប្រកាសនីយបត្រតក្កកម្ម កាន់តែរីកធំធាត់ទៅមុខ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្នើដល់សិក្ខាកាមទាំងអស់ គប្បីត្រងត្រាប់ស្តាប់ និងស្រូបយក នូវចំណេះ និងបទពិសោធន៍ទាំងឡាយ ដែលអង្គសិក្ខាសាលាអាចផ្តល់ជូននាពេលនេះ បើទុកណាជា ពេលវេលានៃសិក្ខាសលាមានកំរិតក៏ដោយ ។

បន្ទាប់មកអង្គសិក្ខាសាលា បានតាមដានស្តាប់នូវបទឧទ្ទេសនាម ជាបន្តបន្ទាប់ ពីអ្នកជំនាញមកពីការិយាល័យប្រកាសនីយបត្រសហគមន៍អឺរ៉ុប គឺលោក **Pascal Phlix** លើប្រធានបទមួយចំនួនដូចជា: –The Institution and of its role in Europ & Worldwide –The Propose Model for the EPO-MIH Co-operation for developing the Cambodian patent system &strentening Cambidian innovation –The Competences of EPO –How the “Validation on-demand” system of European & legal aspects និងបទបង្ហាញស្តីអំពី The objective of technical co-operation in the Contex of the “validation on Demand” system of European patents ។

